ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# របាយការណ៍នៃកម្មវិធីបង្ការ ថែទាំ និងព្យាបាល ជំងឺអេដស៍ និងជំងឺកាមរោគ ពីខែមេសា ដល់ខែមិថុនា ឆ្នាំ ២០២៣

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាពន់ពេក ដែលបានពិនិត្យឃើញថា សមិទ្ធផលដែលសម្រេចបានពីការអនុវត្តកម្មវិធីបង្ការ ថែទាំនិងព្យាបាលជំងឺអេដស៍និងជំងឺកាមរោគក្នុងវិស័យសុខាភិបាលរហូតដល់ត្រីមាសទី ២ ឆ្នាំ២០២៣ នេះ បាន បង្ហាញឲ្យឃើញថាមន្ត្រីសុខាភិបាល ដែលទទួលខុសត្រូវការងារនេះ បានធ្វើកិច្ចសហការគ្នាយ៉ាងស្អិតរមួតជា មួយដៃគូអភិវឌ្ឍន៍ទាំងអស់ និងសហគមន៍ ដោយមានការប្តេជ្ញាចិត្តខ្ពស់ពីគ្រប់បណ្តារាជធានី-ខេត្តនានា ធ្វើឲ្យមានភាពប្រសើរឡើងក្នុងការអនុវត្តកម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងជំងឺកាមរោគ ជូនប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា។ សមិទ្ធផលដែលសម្រេចបានទាំងនេះ បានជម្រុញនិងលើកទឹកចិត្តយើងបន្ថែមទៀត ដើម្បីកំណត់គោលបំណង និងទិសដៅសម្រាប់ឆ្នាំបន្តបន្ទាប់ ឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគ អេដស៍នៅកម្ពុជា និងតម្រូវការរបស់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ឲ្យកាន់តែប្រសើរឡើង។

ខ្ញុំសូមថ្លែងអំណរគុណជូន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល អង្គការដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ ដែលតែងផ្តល់ការគាំទ្រផ្នែកគោលនយោបាយ ទស្សនៈវិស័យ ផ្នែកបច្ចេកទេស និងផ្នែកធនធានលើកម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងជំងឺកាមរោគ នៅប្រទេសកម្ពុជា។

យើងសង្ឃឹមថាលោក លោកស្រី នឹងស្វែងយល់បន្ថែមទៀត ក្រោយពីអានរបាយការណ៍នេះហើយយើងខ្ញុំនឹងទទួលស្វាគមន៍រាល់ការផ្តល់មតិយោបល់កែលម្អការងារនេះឲ្យកាន់តែប្រសើរឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែក និងកាមរោគ**

វេជ្ជ.អ៊ុក វិជ្ជា

# មាតិកា

ៜៜ៚ៜៜ


## ១. សាវតា

១.១ សេចក្ដីផ្ដើម

១.២ ស្ថានភាពអេពីដេមីកនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា

## ២. ប្រព័ន្ធគ្រប់គ្រងនៃមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

២.១ វដ្តនៃការធ្វើផែនការ និងការតាមដានរបស់មជ្ឈមណ្ឌលជាតិ

២.២ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង

២.៣ គោលការណ៍ណែនាំ និង និយាមនៃបែបបទសម្រាប់ប្រតិបត្តិ

២.៤ ការអង្កេតតាមដាន (Surveillance) និងការសិក្សាស្រាវជ្រាវ (Research)

## ៣. សមិទ្ធផលនៃការផ្ដល់សេវា

៣.១. សកម្មភាពបង្ការ ថែទាំ និងព្យាបាលជំងឺកាមរោគ

៣.១.១. ការថែទាំ និងព្យាបាលជំងឺកាមរោគ នៅគ្លីនិកសុខភាពគ្រួសារ

៣.១.២. ការថែទាំ និងព្យាបាលជំងឺកាមរោគ នៅតាមមណ្ឌលសុខភាព

៣.២. សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

៣.២.១ សេវាផ្ដល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់

៣.២.១.១. ការផ្ដល់សេវាមុនធ្វើតេស្តឈាមរកមេរោគអេដស៍

៣.២.១.២. ការផ្ដល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍

៣.២.១.៣. ការផ្ដល់សេវាក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍

៣.២.១.៤. ការផ្ដល់សេវាធ្វើតេស្តឈាមរកករណីឆ្លងថ្មីនៃមេរោគអេដស៍

៣.២.២ សេវាថែទាំ ព្យាបាល និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

៣.២.២.១. សេវាថែទាំ និង ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

៣.២.២.២ ការបញ្ជូនអ្នកជំងឺទៅទទួលសេវាកន្លែងផ្សេងការបោះបង់ការព្យាបាលនិងការស្លាប់

៣.២.២.៣ ការពិនិត្យស្រាវជ្រាវរកករណីជំងឺរបេង លើអ្នកជំងឺអេដស៍ថ្មី

៣.២.២.៣.១. ស្រាវជ្រាវករណីជំងឺរបេង លើអ្នកជំងឺអេដស៍ថ្មីនៅសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

៣.២.២.៣.២ការអនុវត្តយុទ្ធសាស្រ្តThree"I"ការព្យាបាលបង្ការជំងឺរបេងដោយឱសIsoniazid
៣.២.២.៤ ការមានផ្ទៃពោះ និងការរំលូតកូន
៣.២.២.៥ ការព្យាបាលកុមារប្រឈមមុខនឹងការឆ្លងមេរោគអេដស៍

**៤. បញ្ហាប្រឈម**

**៥. មេរៀនជាបទពិសោធន៍**

**៦. សេចក្តីសន្និដ្ឋាន**

# របាយការណ៍នៃការអនុវត្តកម្មវិធីបង្ការ ថែទាំ និងព្យាបាល ជំងឺអេដស៍ និងជំងឺកាមរោគ ចាប់ពីខែមេសាដល់ខែមិថុនាឆ្នាំ ២០២៣

## ១. សាវតា

### ១.១ សេចក្តីផ្តើម

របាយការណ៍នេះ ពិពណ៌នាពីសមិទ្ធផលដែលបានមកពីការអនុវត្តកម្មវិធីបង្ការ ថែទាំ និងព្យាបាល ជំងឺអេដស៍ និងជំងឺកាមរោគចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៣។ របាយការណ៍នេះគឺបានមកពីការប្រមូលទិន្នន័យ និងព័ត៌មានទទួលបានមកពីគ្រប់សេវាទាំងអស់ ដូចជា សេវាថែទាំ និងព្យាបាលជំងឺអេដស៍ មណ្ឌលធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ សេវាធ្វើតេស្តឈាមរហ័សនៅថ្នាក់មណ្ឌលសុខភាព គ្លីនិកសុខភាពគ្រួសារ កម្មវិធីបង្ការ ថែទាំ និងគាំទ្រអ្នកជំងឺអេដស៍តាមសហគមន៍ និងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅទូទាំងប្រទេស បានចងក្រងជារបាយការណ៍គ្រប់ជ្រុងជ្រោយមួយ នៃការឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគអេដស៍និងជំងឺកាមរោគក្នុងវិស័យសុខាភិបាល នៅប្រទេសកម្ពុជា។ របាយការណ៍នេះ ពិពណ៌នាទៅតាមផ្នែកជាបន្តបន្ទាប់គឺផ្តោតលើសកម្មភាពសំខាន់ៗនៃការអនុវត្តកម្មវិធីចាប់ពីដើមខែមករា រហូតដល់ខែមិនា ឆ្នាំ២០២៣ រួមមាន៖

ក. របាយការណ៍ទូទៅទាក់ទងនឹងសកម្មភាពសំខាន់ៗនៃការគ្រប់គ្រងនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី

ខ. លទ្ធផលទទួលបានពីការផ្តល់ពីសេវានានា

គ. ឧបសគ្គនានាដែលបានជួបប្រទះ

ឃ. មេរៀនជាបទពិសោធន៍

ង. សេចក្តីសន្និដ្ឋាន

### ១.២ ស្ថានភាពអេពីដេមីកនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា

ក្រោយពីបានរកឃើញមេរោគអេដស៍លើកដំបូងនៅឆ្នាំ ១៩៩១ អត្រាឆ្លង បានរីករាលដាលយ៉ាងខ្លាំង ដោយសារមានការកើនឡើងនូវឧស្សាហកម្មផ្លូវភេទ ចន្លោះពីឆ្នាំ១៩៩៥ ទៅឆ្នាំ ១៩៩៨ ដែលអត្រាប្រេវ៉ាឡង់ នៃជំងឺអេដស៍បានកើនឡើងជិត២ ដង គឺ ពី១,២ % ទៅ ២%។ ដោយមានការចូលរួម និងគាំទ្រយ៉ាងពេញ ទំហឹង និងទាន់ពេលវេលា ពីថ្នាក់ដឹកនាំកំពូលនៃរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ទាំងអស់ និងការចូលរួម អនុវត្ត គ្រប់លំដាប់ថ្នាក់ក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ដ៏មានប្រសិទ្ធភាព ប្រទេសកម្ពុជាបាន ទទួលជោគជ័យដែលធ្វើឲ្យអត្រាប្រេវ៉ាឡង់បានថយចុះពី ០,៩% នៅឆ្នាំ២០០៦ មក ០,៥០% នៅឆ្នាំ ២០២២ ដែលបានធ្វើការប៉ាន់ប្រមាណនៃករណីឆ្លងមេរោគអេដស៍ថ្មីមានចំនួន១.៤០០ នាក់ និងអ្នកជំងឺអេដស៍មានចំនួន ៧៦.០០០ នាក់ ក្នុងឆ្នាំ២០២២ (ទិន្នន័យនៃការប៉ាន់ប្រមាណ- Spectrum AIM 2023)។ ការថយចុះនៃអត្រា ប្រេវ៉ាឡង់ និងអត្រាអាំងស៊ីដង់ នៃការឆ្លងមេរោគអេដស៍នៅប្រទេសកម្ពុជា គឺជាលទ្ធផលបានមកពីការខិតខំប្រឹង ប្រែងដ៏ខ្លាំងក្លាក្នុងការអនុវត្តកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ក្នុងចំណោមស្ត្រីបម្រើសេវាផ្លូវភេទនៅ តាមផ្ទះបនចាប់តាំងពីឆ្នាំ ១៩៩៨ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល និងមានការចូលរួមសហការយ៉ាងពេញ ទំហឹងពីគ្រប់លំដាប់ថ្នាក់។ ការថយចុះនៃអត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅ យើងក៏កត់សំគាល់ថាក្រុមប្រជាជនចំណុចដូចជា ស្ត្រីបម្រើសេវាកំសាន្ត អ្នកចាក់គ្រឿងញៀន និងក្រុមបុរស ស្រឡាញ់បុរស គឺនៅតែជាក្រុមគោលដៅដែលត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាបង្ការ ថែទាំ និង ព្យាបាលជំងឺអេដស៍។ យោងតាមលទ្ធផលនៃការអង្កេត IBBS (Integrated Bio-Behavioral Survey) នៅឆ្នាំ ២០២២ និន្នាការនៃអត្រាប្រើស្រោមអនាម័យក្នុងចំណោមស្ត្រីបម្រើសេវាកំសាន្ត នៅតែរក្សាបានក្នុងកម្រិតខ្ពស់ ចាប់ពី៨១.០០%ក្នុងឆ្នាំ២០១០ ដល់៩៣.៨៤% ក្នុងឆ្នាំ ២០២២ ក៏ប៉ុន្តែអត្រាប្រើស្រោមអនាម័យជាមួយសង្សារ នៅតែមានកម្រិតទាប (៥៤.៥០%) ក្នុងឆ្នាំ ២០២២។

## ២. ប្រព័ន្ធគ្រប់គ្រងនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

### ២.១ វដ្តនៃការធ្វើផែនការនិងការតាមដានរបស់មជ្ឈមណ្ឌលជាតិ

សិក្ខាសាលាស្តីពី "ការពិនិត្យលើសមិទ្ធផលនៃការអនុវត្តសកម្មភាពឆ្នាំ២០២២ និងការរៀបចំផែនការ ប្រតិបត្តិសម្រាប់អនុវត្តសកម្មភាពបង្ការ ថែទាំនិងព្យាបាលជំងឺអេដស៍និងជំងឺកាមរោគក្នុងវិស័យសុខាភិបាលឆ្នាំ ២០២៣" ត្រូវបានរៀបចំ នៅក្នុងខែធ្នូ ឆ្នាំ ២០២២ នៅខេត្តសៀមរាប។

### ២.២ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង

នៅដើមឆ្នាំ ២០២៣ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានចុះកិច្ចព្រមព្រៀងជាមួយនឹងអង្គការដៃគូអនុវត្តន៍ការងារជាពិសេសការអនុវត្តកម្មវិធីអេដស៍ក្នុងគម្រោងមូលនិធិសកលឆ្នាំ ២០២១ - ២០២៣ មានចំនួន ៩ ដែលក្នុងនោះមានស្ថាប័នរដ្ឋជាដៃគូចំនួន ០២ (NAA, DMHSA, KHANA, RHAC, FI, HACC, CRS, SCHC, CSC) ។ ដោយឡែកនៅដើមឆ្នាំ ២០២៣ មន្ទីរសុខាភិបាលរាជធានី-ខេត្ត ក៏បានចុះហត្ថលេខាជាមួយមជ្ឈមណ្ឌលជាតិលើចំនួនថវិកាសរុបក្នុង ឆ្នាំ២០២៣ ដែលឧបត្ថម្ភដោយមូលនិធិសកល តាមរយៈមជ្ឈមណ្ឌលជាតិ សម្រាប់ការអនុវត្តកម្មវិធីបង្ការ ថែទាំ និង ព្យាបាលជំងឺអេដស៍និងជំងឺកាមរោគ ជាពិសេសការបញ្ជូនឈាមពិនិត្យចំនួនបន្ទុកមេរោគអេដស៍ សម្រាប់ឆ្នាំ២០២៣ នេះ ផងដែរ។

### ២.៣ គោលការណ៍ណែនាំ និងនិយាមនៃបែបបទសម្រាប់ប្រតិបត្តិ

គោលការណ៍ណែនាំនិងនិយាមនៃបែបបទសម្រាប់ប្រតិបត្តិមួយចំនួនត្រូវបានរៀបចំនិង ពិនិត្យឡើងវិញដែលអនុម័តក្នុងត្រីមាសទី ១ និងទី២ ឆ្នាំ២០២៣ ក្នុងគោលបំណងផ្សព្វផ្សាយ និងជំរុញប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺ អេដស៍នៅគ្រប់លំដាប់ថ្នាក់ មានដូចជា៖

- និយាមបែបបទសម្រាប់អនុវត្ត (SOP) សម្រាប់ការអនុវត្តសេវារណប សម្រាប់ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ នៅកម្ពុជា អនុម័តនៅ ខែមករា ឆ្នាំ ២០២៣។

### ២.៤ ការអង្កេតតាមដាន (Surveillance) និងសិក្សាស្រាវជ្រាវ (Research)

ការអង្កេតតាមដានការប្រព្រឹត្ត និងការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំលែងភេទ (IBBS for MSM/TG) ក្នុងឆ្នាំ ២០២៣ កំពុងដំណើរការចុះប្រមូលទិន្នន័យ។

## ៣. សមិទ្ធផលនៃការផ្តល់សេវា

### ៣.១. សកម្មភាពបង្ការ ការថែទាំ និងព្យាបាលជំងឺកាមរោគ

### ៣.១.១. ការថែទាំ និងព្យាបាលជំងឺកាមរោគ នៅគ្លីនិកសុខភាពគ្រួសារ

គ្លីនិកសុខភាពគ្រួសារមានចំនួនសរុប ៥៨ កន្លែង ដែលក្នុងនោះមាន ៣៦ កន្លែងគ្របដណ្តប់លើ ២៥ រាជធានី-ខេត្ត ទូទាំងប្រទេសកម្ពុជា និង ២២ គ្លីនិកស្ថិតក្រោមការគ្រប់គ្រងនិងផ្តល់សេវាដោយអង្គការមិនមែនរដ្ឋាភិបាល (អង្គការរ៉ាក់ ចំនួន ១៥ គ្លីនិក ឃ្យូកស ចំនួន ០១ គ្លីនិក និងអង្គការម៉ារីស្តុបចំនួន ៦ គ្លីនិក)។

ក្នុងចំណោម ៣៦ គ្លីនិកសុខភាពគ្រួសារ ដែលដំណើរការដោយសេវាសុខភាពសាធារណៈ ដែលបានបញ្ចូលទៅក្នុងមន្ទីរពេទ្យបង្អែកត្រូវបានបំពាក់ឧបករណ៍បន្ថែមសំរាប់មន្ទីរពិសោធន៍ ដែលអាចធ្វើតេស្តRPR និង microscopy និងមន្ទីរពិសោធន៍ដែលមាននៅក្នុងគ្លិនីកសុខភាពគ្រួសារទាំង៣៦ជាជំនួយលើសេវាគ្លីនីកក្នុងការគ្រប់គ្រងថែទាំនិងព្យាបាលជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាឲ្យកាន់តែភាពប្រសើរឡើងសម្រាប់ក្រុមប្រជាជនចំណុច ។

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣ ការពិគ្រោះជំងឺកាមរោគនៅតាមគ្លីនិកសុខភាពគ្រួសារទាំងនោះ បានទទួលការពិគ្រោះជំងឺទាំងអស់ ៤៤.៨៨៩ ករណី ក្នុងនោះមាន៧.៣៤១នាក់ ជាបុរស និង ៩៥៩នាក់ ជាក្រុមបុរសស្រឡាញ់បុរស ៣៥.២៧១នាក់ ជាស្ត្រីដែលមានប្រឈមមុខទាប ៩៧១នាក់ជាស្ត្រីបម្រើការនៅសេវាកំសាន្ត និង ៣៤៧ នាក់ទៀតដែលជាស្ត្រីបម្រើការនៅសេវាកំសាន្ត បានមកធ្វើការពិនិត្យតាមដានបន្តជារៀងរាល់ខែ។

គ្លីនិកសុខភាពគ្រួសារទាំង៣៦ កន្លែង បានរាយការណ៍ពីករណីព្យាបាលជំងឺកាមរោគ តាមចង្កោមរោគសញ្ញា ដូចខាងក្រោម៖

- បុរសមានករណីជំងឺកាមរោគចំនួន៥.៧១៧ករណី ដែលក្នុងនោះមាន ២.៩៣៤(៥១,៣២%) ករណីមានហូរខ្ទុះតាមបង្ហួរនោម ១០(០,១៧%)ករណីមានហូរខ្ទុះតាមរន្ធគូថ៩៨៤(១៧,២១%)ករណីមានដំបៅលើប្រដាប់បន្តពូជនិងរន្ធគូថ ៤៨១(៨,៤១%)ករណីមានសិរមាន់លើប្រដាប់បន្តពូជនិងរន្ធគូថ ៣(០,០៥%) ករណីមានហើមពងស្វាស ២១(០,៣៦%) ករណីហើមក្រលៀន ៥៣២(៩,៣០%) ករណីស្វាយ ២៤៩ (៤,៣៥%) ករណីស្វាយតាមដាន និង៥០៣(៨,៧៩%) ករណីផ្សេងៗ។
- ក្នុងចំណោមបុរសបុរសស្រឡាញ់បុរស (MSM) មានជំងឺកាមរោគចំនួន ៦៨៨ករណី ដែលក្នុងនោះមាន ២៦១(៣៧,៩៣%)ករណីមានការហូរខ្ទុះតាមបង្ហួរនោម ៣(០,៤៣%)ករណីមានហូរខ្ទុះតាមរន្ធគូថ ១៣៧(១៩,៩១%)ករណីមានដំបៅលើប្រដាប់បន្តពូជនិងរន្ធគូថ ៣២(៤,៦៥%) ករណីមានសិរមាន់លើប្រដាប់បន្តពូជ ៧(១,០១%)ករណីហើមពងស្វាស ១៩៤(២៨,១៩)ករណីស្វាយ ៥០(៧,២៦%)ករណីស្វាយតាមដាន និង៤(០,៥៨%) ករណផ្សេងៗ
- ចំណោមស្ត្រីមានការប្រឈមមុខទាប បានរាយការណ៍មានករណីជំងឺកាមរោគ តាមចង្កោមរោគសញ្ញាចំនួន ២៩.៨៤៩ករណី ដែលក្នុងនោះមាន ៦០០៥(២០,១១%)ករណីមានជំងឺរលាកទ្វារមាស ១៨.៥៩៦(៦២,៣០%)ករណីមានជំងឺរលាកមាត់ស្បូន៩៨៥ (៣,៣៩%)ករណីមានជំងឺរលាក ទ្វារមាស និងមាត់ស្បូន ១០១(០,៣៣%)ករណីមានជំងឺរលាកប៉ែលវីស ១.០០០(៣,៣៥%) ករណីមានជំងឺដំបៅ

លើប្រដាប់បន្តពូជ/រន្ធគូថ៥៥០(១,៨៤%)ករណីជំងឺសិរមាន់លើប្រដាប់បន្តពូជ/រន្ធគូថ ៤៩១(១,៦៤) ករណីស្វាយ ២៥៤(០,៨៥%)ករណីស្វាយតាមដាន និង១៨៦៧(៦,២៥%) ករណីផ្សេងៗ។

### ៣.១.២. ការថែទាំ និងព្យាបាលជំងឺកាមរោគ នៅតាមមណ្ឌលសុខភាព

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣នេះ មណ្ឌលសុខភាពចំនួន ២៣៤កន្លែងដែលស្ថិតនៅក្នុងស្រុកប្រតិបត្តិចំនួន ៧៧ ក្នុង ២៥ រាជធានី-ខេត្ត បានផ្តល់សេវាពិនិត្យជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា។ អ្នកជំងឺមកពិគ្រោះចំនួនសរុប ៥.៣២៣នាក់ (បុរសចំនួន ៤៧២នាក់ និង ស្ត្រីចំនួន ៣.២៥១នាក់ និង ដៃគូជាបុរស ចំនួន ៣១០នាក់ និងដៃគូជាស្ត្រី ចំនួន ១.២៩០នាក់ )។ ករណីឆ្លងថ្មីនៃជំងឺកាមរោគសរុបមាន ៣៩៥៨.ករណី(បុរស៤៤៤ករណី ស្ត្រី៣.១៩១ ករណី) ដែលក្នុងចំណោមករណីជំងឺទាំងនេះមានលទ្ធផលដូចខាងក្រោម៖

- អ្នកជំងឺកាមរោគបុរសបានមកពិភាក្សានិងពិនិត្យជំងឺ នៅមណ្ឌលសុខភាព ចំនួន ៤៤៥ករណី
- ដែលក្នុងនោះមាន៖
    - ហូរខ្ទុះតាមបង្ហូរនោម ៣៧៥(៨៤,២៣%)
    - ដំបៅលើប្រដាប់បន្តពូជ ៦៤(១៤,៤១%)
    - ករណីជំងឺ សិរមាន់លើប្រដាប់បន្តពូជ ៦(១,៣៥%)
- អ្នកជំងឺកាមរោគស្ត្រីបានមកពិភាក្សានិងពិនិត្យជំងឺកាមរោគនៅមណ្ឌលសុខភាព ចំនួន៣.១៩១ ករណីដែលក្នុងនោះមាន ៖
    - រលាកទ្វារមាស ១.៦៨៧(៥២,៨៦%)
    - រលាកទ្វារមាសនិងមាត់ស្បូន ១.២៨៩ (៤០,៣៩%)
    - រលាកប៉ែលវីស ១៣៣(៤,១៦%)
    - ដំបៅលើប្រដាប់បន្តពូជ ១០(០,៣១%)
    - ជំងឺសិរមាន់ ៧២(២,២៥%)

## ៣.២. សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

### ៣.២.១ សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ (VCCT)

ត្រឹមត្រីមាសទី២ឆ្នាំ២០២៣ មណ្ឌលផ្តល់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម VCCT ៧២កន្លែង និងព្យាបាលជំងឺអេដស៍តែប៉ុណ្ណោះ ដែលដើរតួនាទីដ៏សំខាន់ក្នុងការធ្វើតេស្តបញ្ជាក់រកមេរោគអេដស៍មុននឹងចាប់

ផ្ដើមព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍។ ក្នុងចំណោមមណ្ឌលផ្ដល់សេវា VCCT ទាំង ៧២ មាន ៦៩ កន្លែង ដែលស្ថិតក្រោមការគ្រប់គ្រងដោយសេវាសុខភាពសាធារណៈនៅសេវា ART ក្នុងមន្ទីរពេទ្យ និង ០៣ កន្លែងដំណើរការដោយ អង្គការមិនមែនរដ្ឋាភិបាល (កុមារអង្គរខេត្តសៀមរាប អង្គការ Center of Hope ១ និង គ្លីនិកឈូកស១កន្លែង)។ ក្នុងចំណោម សេវា VCCT ទាំង ៧២ កន្លែង មាន ផ្តល់សេវាធ្វើតេស្តឈាមរកករណីឆ្លងថ្មីនៃមេរោគអេដស៍ (Recency test)។ ទន្ទឹមនឹងនេះ សេវាធ្វើតេស្តឈាមរកមេរោគអេដស៍រហ័សដោយជោះឈាមនៅចុងម្រាមដៃ ត្រូវបានពង្រីកដល់មណ្ឌលសុខភាព ដែលមានចំនួនជាង ១.១២១ កន្លែង ។

### ៣.២.១.១. ការផ្តល់សេវាមុនធ្វើតេស្តឈាមរកមេរោគអេដស៍

គិតត្រឹមត្រីមាសទី២ឆ្នាំ២២០៣ មានអតិថិជនទាំងអស់ចំនួន៨.៨១០នាក់ ដែលបានមកទទួលសេវាផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមរកមេរោគអេដស៍នៅ VCCT ដែលក្នុងនោះមានចំនួន ១៤៧(១,៦៦%) ស្ត្រីបម្រើសេវាកម្សាន្ត ចំនួន១.១១៥(១២,៦៥%)បុរសស្រឡាញ់បុរស ចំនួន២៣៥(២,៦៦%)ក្រុមប្លែងភេទ ចំនួន៣(00%) បុរសបម្រើសេវាកម្សាន្ត ចំនួន២៨(0,31%)អ្នកប្រើប្រាស់គ្រឿងញៀន ចំនួន0(00%)អ្នកចាក់គ្រឿងញៀន ចំនួន៦.៨៩៣(៧៨,២៤%)ប្រជាជនទូទៅ ចំនួន៣៨៥(៤,៣៧%)ស្ត្រីផ្ទៃពោះ ស្ត្រីក្រោយសំរាល និង ៤ (0,0៤%) ដៃគូរ។

### ៣.២.១.២. ការផ្តល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣អតិថិជនដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវា VCCT មានចំនួន៨.៨០០ នាក់ក្នុងនោះអ្នកបានធ្វើតេស្តមានលទ្ធផលវិជ្ជមានមានចំនួន១.២៣៥នាក់។

### ៣.២.១.៣. ការផ្តល់សេវាក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣ មានអតិថិជនដែលបានធ្វើតេស្តឈាមទាំងអស់ចំនួន ៨.៨០០នាក់ ដែលក្នុងនោះមានអតិថិជនទទួលការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍ចំនួន ៨.១៣២នាក់(៩២,៤០%)

### ៣.២.១.៤. ការផ្តល់សេវាធ្វើតេស្តឈាមរកករណីឆ្លងថ្មីនៃរកមេរោគអេដស៍

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣ មានអតិថិជនដែលបានធ្វើតេស្តឈាមរកករណីឆ្លងថ្មីនៃមេរោគអេដស៍ ទាំងអស់ចំនួន ៥៦នាក់ ដែលក្នុងនោះមានអតិថិជនមានលទ្ធផលវិជ្ជមានសម្រាប់ករណីឆ្លងថ្មីនៃមេរោគអេដស៍ ចំនួន ៣៨នាក់។

### ៣.២.២. សេវាថែទាំ ព្យាបាលជំងឺ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

#### ៣.២.២.១. សេវាថែទាំ និង ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

គិតត្រឹម ត្រីមាសទី២ឆ្នាំ២០២៣ មានសេវាថែទាំនិងព្យាបាលជំងឺឱកាសនិយមនិងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន ៧៣ កន្លែង នៅក្នុង ២៥ រាជធានី-ខេត្ត បានបញ្ជូនទិន្នន័យមកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ។ ក្នុងចំណោម សេវាទាំង ៧៣ កន្លែង គឺ សេវាចំនួន ៧១ កន្លែង ស្ថិតនៅក្រោមការគ្រប់គ្រងដោយរដ្ឋាភិបាល និងសេវាចំនួន ២ កន្លែងទៀតដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល (Center of Hope ១ និង គ្លីនិកឈូកស១កន្លែង) និងមានសេវាទទួលការពិនិត្យនិងព្យាបាលជំងឺកុមារផ្ទុកមេរោគអេដស៍ចំនួន ៤១ កន្លែង។

គិតត្រឹម ត្រីមាសទី២ឆ្នាំ២០២៣ មានអ្នកជំងឺដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ចំនួន៦៦,២៥៧នាក់ ដែលក្នុងនោះអ្នកជំងឺសកម្មកំពុងទទួលឱសថប្រឆាំងនឹងមេរោគអេដស៍ សរុបចំនួន ៦៦,២៣៥នាក់(៦៤,៩១៥នាក់ជាមនុស្សពេញវ័យ និង១.៣២០នាក់ជាកុមារ) ។

អ្នករស់នៅជាមួយមេរោគអេដស៍(មនុស្សពេញវ័យ និងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានធ្វើតេស្ត Viral Load ហើយមានលទ្ធផល Viral Load Suppressed ចំនួន ៩៨,០១% (៥១៤៧៣/៥២៥១៧)។

#### ៣.២.២.២ ការបញ្ជូនអ្នកជំងឺទៅទទួលសេវាកន្លែងផ្សេង ការបោះបង់ការព្យាបាល និងការស្លាប់

គិតត្រឹម ត្រីមាសទី២ឆ្នាំ២០២៣ មានចំនួនអ្នកជំងឺដូចខាងក្រោម៖

- អ្នកជំងឺដែលចាប់ផ្តើមទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ចំនួន១.២៣៤នាក់ (មនុស្សពេញវ័យចំនួន ១.២០៩នាក់ និង កុមារចំនួន ២៥នាក់)។
- អ្នកជំងឺដែលបានបញ្ជូនចូលមកទទួលសេវា ART ក្នុងត្រីមាសនេះ មានចំនួន ៣២០នាក់ (មនុស្សពេញវ័យចំនួន ៣១៥ នាក់ និង កុមារមានចំនួន០៥ នាក់)។
- អ្នកជំងឺដែលបានបញ្ជូនចេញ ក្នុងត្រីមាសនេះ មានចំនួន ៣៧១នាក់ (មនុស្សពេញវ័យចំនួន ៣០៤ នាក់ និង កុមារមានចំនួន៦៧ នាក់)។
- អ្នកជំងឺដែលបានបោះការព្យាបាលមានចំនួនសរុប ៥៥០នាក់ (មនុស្សពេញវ័យចំនួន៥១៤ នាក់ និង កុមារចំនួន ១៤នាក់) ។

- អ្នកជំងឺចំនួន២៣៣ នាក់ (មនុស្សពេញវ័យចំនួន២២៧នាក់ និងកុមារចំនួន ៦ នាក់) ផ្សេងទៀតត្រូវបាន រាយការណ៍ថាស្លាប់ ។

### ៣.២.២.៣ ការពិនិត្យស្រាវជ្រាវរកករណីជំងឺរបេង លើអ្នកជំងឺអេដស៍ថ្មី

#### ៣.២.២.៣.១.ស្រាវជ្រាវករណីជំងឺរបេងលើអ្នកជំងឺអេដស៍ថ្មីនៅសេវាព្យាបាលឱសថប្រឆាំងមេរោគអេដស៍

គិតត្រឹម ត្រីមាសទី២ឆ្នាំ២០២៣ អ្នកជំងឺអេដស៍ថ្មីដែលបានចុះឈ្មោះនៅកន្លែងផ្តល់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍(ART services ) មានចំនួន ១.២៣៤នាក់ (មនុស្សពេញវ័យចំនួន ១.២០៩ នាក់ និងកុមារចំនួន ២៥ នាក់)។ នៅក្នុងចំណោមនោះមនុស្សពេញវ័យ ចំនួន ១៥៣ នាក់(១២,៦៥%) និងកុមារចំនួន0 នាក់ បានធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង។ ក្នុងនោះ ចំនួន ៥0 នាក់ (៤,១៣%) បានចាប់ផ្តើមទទួលការព្យាបាលជំងឺរបេង។

#### ៣.២.២.៣.២ ការអនុវត្តយុទ្ធសាស្ត្រ Three "I" ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid (IPT)

គិតត្រឹម ត្រីមាសទី២ឆ្នាំ២០២៣ នេះ មានតែអ្នកជំងឺអេដស៍ពេញវ័យចំនួន ១.៦៦៩នាក់ និងកុមារចំនួន ៣0នាក់ បានចាប់ផ្តើមព្យាបាលបង្ការជំងឺរបេងដោយឱសថ (TPT) ។

### ៣.២.២.៤ ការមានផ្ទៃពោះ និងការរំលូតកូន

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣ ស្ត្រីមានផ្ទៃពោះកំពុងព្យាបាលមានចំនួន ១១២ នាក់(១៧នាក់ មានផ្ទៃពោះមុនមកទទួលការព្យាបាល និង៩៥នាក់ មានផ្ទៃពោះក្នុងពេលកំពុងទទួលការព្យាបាល )។ ស្ត្រីមានផ្ទៃពោះចំនួន ១៥នាក់ត្រូវបានរាយការណ៍ថា មានករណីរលូតកូន៩ និងមានករណីរំលូតកូនចំនួន៦នាក់។

### ៣.២.២.៥ ការព្យាបាលកុមារប្រឈមមុខនឹងការឆ្លងមេរោគអេដស៍

គិតត្រឹមត្រីមាសទី ២ ឆ្នាំ២០២៣ មានកុមារថ្មីប្រឈមនឹងការឆ្លងមេរោគអេដស៍បានចុះឈ្មោះនិងទទួលការព្យាបាលចំនួន ៨៤នាក់ ។

- កុមារដែលបានធ្វើតេស្តនិងទទួលលទ្ធផលតេស្ត DNA PCR លើកទី១ ចំនួន ៥៩នាក់ (ក្នុងនោះទទួលលទ្ធផលតេស្តDNA PCR វិជ្ជមានលើកទី១ចំនួន 0២នាក់ អវិជ្ជមានចំនួន ៤៨នាក់ និងរង់ចាំលទ្ធផលចំនួន ៩នាក់) ។

- កុមារបានធ្វើតេស្តបញ្ជាក់លើលទ្ធផល DNA PCR លើកទី១ ចំនួន ៣ នាក់ (វិជ្ជមានចំនួន០០ នាក់ អវិជ្ជមាន ៣ នាក់ និងរង់ចាំលទ្ធផលចំនួន ០០នាក់។
- គិតត្រឹមត្រីមាសទី ២ ឆ្នាំ២០២៣ កុមារដែលបានធ្វើតេស្ត DNA PCR លើកទី២ ចំនួន៣៨នាក់(វិជ្ជមាន ០១ អវិជ្ជមានចំនួន ៣២នាក់ និងរង់ចាំលទ្ធផលចំនួន ៥នាក់) និងបានធ្វើតេស្តបញ្ជាក់លើលទ្ធផល DNA PCR លើកទី២ចំនួន ០១នាក់ដោយលទ្ធផលតេស្តវិជ្ជមាន។

គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣ នេះកុមារចាកចេញពីការព្យាបាលមានចំនួន ៨៦នាក់ ក្នុងនោះមាន៖

- កុមារដែលមានលទ្ធផលបញ្ជាក់ថា HIV(-) បញ្ឈប់ការព្យាបាល ចំនួន ៥៤នាក់ និង
- កុមារដែលលទ្ធផលបញ្ជាក់ថា HIV(+) ៥ នាក់ ដែលត្រូវទទួលទទួលការព្យាបាលនៅសេវាព្យាបាលជំងឺឱកាសនិយម និងដោយឱសថប្រឆាំងមេរោគអេដស៍។
- ចំនួនកុមារស្លាប់ចំនួន ០០ នាក់ និង លះបង់ការព្យាបាលចំនួន ២៧នាក់។

ដោយលែកគិតត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៣ របាយការណ៍មកពីផ្នែកមន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ មានទារកប្រឈមនឹងការឆ្លងមេរោគអេដស៍ក្នុងកំឡុងពេល ២ ខែបន្ទាប់ពីកើត បានធ្វើតេស្ត DNA PCR ចំនួន ១៣៩ នាក់ ក្នុងនោះមានលទ្ធផលវិជ្ជមាន០៣នាក់។

## ៤. បញ្ហាប្រឈម

- ការរីករាលដាលមេរោគកូវីដ ១៩នៅសហគមន៍បានថយឥទ្ធិពលដែលអាចធ្វើឱ្យការអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនមានការកើនឡើងដូចជា៖
  - ការចុះអប់រំផ្ទាល់សម្រាប់ការបង្ការការចម្លងមេរោគអេដស៍ និងធ្វើតេស្តឈាមរកមេរោគអេដស៍ដល់ក្រុមគោលដៅត្រូវបានបន្តនិងពង្រឹងការអនុវត្ត ដូច្នេះធ្វើឱ្យលទ្ធផលមានចំនួនកើនឡើងបើធៀបជាមួយនឹងត្រីមាសមុន។
  - អ្នកជំងឺអេដស៍ដែលត្រូវមកទទួលសេវា ART តាមការណាត់ និងការបញ្ជូនឈាមសម្រាប់ ពិនិត្យ CD4 និង Viral Load មានចំនួនកើនឡើង។
  - ការដឹកនាំចុះអង្កេតតាមដាន និង ស្រាវជ្រាវសម្រាប់ ក្រុមបុរសរួមភេតជាមួយបុរសនិងក្រុមបំលែងភេទបាន ចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ ២០២៣។
- ថវិកាដែលអនុម័តនៅក្នុងគម្រោងនានាជាពិសេសមូលនិធិសកលមានកម្រិតសម្រាប់ឆ្នាំនីមួយៗ ដែលមិនអាចធ្វើឱ្យការសម្រេចបានពេញលេញទៅតាមគោលដៅដែលបានកំរិតនៅក្នុងផែនការយុទ្ធសាស្ត្រ និងមិនសមស្របទៅតាមការអនុវត្តវិធីសាស្ត្រថ្មីៗ ដើម្បីឆ្លើយតបនឹងជំងឺអេដស៍។

## ៥. មេរៀនជាបទពិសោធន៍

- ការសម្របសម្រួល និងកិច្ចសហការល្អ ជាមួយដៃគូអភិវឌ្ឍន៍ អាជ្ញាធរដែនដី សេវាសុខាភិបាលគ្រប់លំដាប់ថ្នាក់ និងសហគមន៍ គឺជាគន្លឹះនៃការអនុវត្តន៍កម្មវិធីបានជោគជ័យ។
- ភាពជាដៃគូរវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ សើស្បែក និងកាមរោគ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន ព្រមទាំងមានការគាំទ្រពីក្រសួងសុខាភិបាល គឺជាការងាររួមដ៏មានសារៈសំខាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងការចូលរួមសហការគ្នាក្នុងការអនុវត្តសកម្មភាពនៅតាមថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ នាំឲ្យសម្រេចបានលទ្ធផលនៃការអនុវត្តកម្មវិធីអេដស៍ និងកាមរោគចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០២៣ និងត្រូវពង្រឹងភាពជាដៃគូនេះបន្ថែមទៀត សម្រាប់ការអនុវត្តការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍នៅឆ្នាំបន្តបន្ទាប់។
- ពង្រឹងការអប់រំនៅក្នុងសហគមន៍និងក្រុមប្រជាជនចំណុច តាមរយៈការចុះអប់រំផ្ទាល់ និង online ដើម្បីជំរុញឲ្យក្រុមប្រជាជនចំណុច មកទទួលសេវាបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ ជំងឺកាមរោគ វាជាកត្តាចាំបាច់ និង អាចធានាឲ្យក្រុមនេះអាចទទួលសេវាបានជាសកល ។
- **៦. សេចក្តីសន្និដ្ឋាន**

ជារួម មជ្ឈមណ្ឌលជាតិ ដោយមានកិច្ចសហការគាំទ្រពីដៃគូរទាំងអស់ សម្រេចបានគោលដៅដែលបានលើកឡើងក្នុងកំឡុងពេលនៃត្រីមាសទី ២ ឆ្នាំ២០២៣ ហើយយើងអាចសន្និដ្ឋានថា ការធ្វើការងារជាដៃគូរក្នុងការបង្ការ ថែទាំនិងព្យាបាលជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជានឹងឈានទៅសម្រេចគោលដៅនាពេលអនាគត។ ទោះជាយ៉ាងនោះក៏ដោយ គួរតែធានាឲ្យបាននូវការប្តេជ្ញាចិត្ត បន្តការគាំទ្រទាំងផ្នែកបច្ចេកទេស ផ្នែកនយោបាយ និងធនធានថវិកាដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ។ ប្រសិនបើអង្គការដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ កាត់បន្ថយការជួយគាំទ្រដល់ការងារប្រយុទ្ធទប់ស្កាត់នឹងការរីករាលដាលនៃជំងឺអេដស៍នេះឆាប់ពេក នៅពេលដែលថវិការាជរដ្ឋាភិបាលនៅមានកម្រិតអាចនឹងធ្វើឲ្យប្រទេសកម្ពុជា មានការលំបាកក្នុងការបន្តនិរន្តភាពប្រកបដោយជោគជ័យលើការងារនេះ។